


**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

**COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)**

**ទីស្នាក់ការកណ្តាលផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 Fax: (855) 23 885 745
E-mail: comfrel@online.com.kh Website: http://www.comfrel.org



**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

1.លោក ធន សារាយ
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

2.លោក សុក សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

3.លោក យង់ គិមអេង
Mr. YONG Kim Eng
អគ្គហេរញ្ញិក -នាយកប្រតិបត្តិ
PDP-Center

4.លោក យឹម ប៉ូ
Mr. YIM Po នាយករង
CPDEW

5.អ្នកស្រី ស៊ុន ចាន់សែន
Mrs. SUN Chansen
ឥស្សរជន- Dignitary

6.លោក ម៉ាក់ ចំរើន
Mr. MAK Chamroeun
ប្រធាន KYA

7.អ្នកស្រី ប៉ុក បញ្ញាវិចិត្រ
Mrs. POK Panhavichetr
នាយិកាប្រតិបត្តិ CWCC

8.លោក មុំ សារិន
Mr. MOM Sarin
នាយក HRCDO

9.លោកស្រី ពឹង យក់ហៀប
Ms. PEUNG Yok Hiep
ឥស្សរជន-Dignitary

10. លោក គឹម សុវណ្ណ
Mr. KIM Sovann
នាយក VIGILANCE

11.លោក សឺន សែត
Mr. SEN Set
ឥស្សរជន-Dignitary

12. លោក ជាំង សុខា
Mr. CHEAMG Sokha
នាយកប្រតិបត្តិ YRDP


ភ្នំពេញថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១២

# សេចក្តីថ្លែងការណ៍
## ស្តីពី
## របាយការណ៍បរិយាកាសនៅថ្ងៃស និងថ្ងៃបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២

ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នេះ ជាជំហានបន្ថែមមួយក្នុងការពង្រឹងអភិបាលកិច្ចលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋានក្នុងប្រទេសកម្ពុជា ។ ទោះបីយ៉ាងណា ខុមហ្វ្រែលសង្កេតឃើញថា បរិយាកាសមុនថ្ងៃបោះឆ្នោតមួយថ្ងៃ (ថ្ងៃស) និងថ្ងៃបោះឆ្នោតមានភាពស្ងប់ស្ងាត់ល្អ ។ នៅថ្ងៃស ខុមហ្វ្រែលរកឃើញថា គណបក្សនយោបាយយ៉ាងហោចចំនួនពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសមរង្ស៊ី ចំនួនប្រមាណ ៥ ករណី បានបន្តការឃោសនាដែលត្រូវបានហាមឃាត់ដោយច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានកើតឡើងនៅខេត្តព្រៃវែង បន្ទាយមានជ័យ តាកែវ និងកោះកុង ដូចជាការ ឃោសនាចាក់មេក្រូ ការចែកលុយ និងសម្ភារៈផ្សេងៗ និងលើកបដាគណបក្ស ។ ខុមហ្វ្រែលសង្កេតឃើញក្នុងថ្ងៃបោះឆ្នោត ទោះបីពុំមានសកម្មភាពណាមួយដែលអាចបង្កឲ្យដំណើរការបោះឆ្នោត មិនបានជួបភាពមិនប្រក្រតីធ្ងន់ធ្ងរ រហូតធ្វើឲ្យរាំងស្ទះដំណើរការនៅថ្ងៃបោះឆ្នោតនៅការិយាល័យណាមួយឡើយ ។ អ្នកសង្កេតការណ៍ខុមហ្វ្រែលរកឃើញភាពមិនប្រក្រតីមួយចំនួន ដូចជាបញ្ហាខុសទិន្នន័យ ព័ត៌មាន រវាងឯកសារបញ្ជាក់អត្តសញ្ញាណ និងបញ្ជីឈ្មោះ ការរារាំងអ្នកសង្កេតការណ៍មិនឲ្យចូលសង្កេតក្នុងការិយាល័យបោះឆ្នោត និងជាពិសេសមានវត្តមានអាជ្ញាធរនៅក្បែរការិយាល័យបោះឆ្នោត។ ល។

នៅថ្ងៃបោះឆ្នោតខុមហ្វ្រែលមានការព្រួយបារម្ភពីគុណភាពនៃទឹកខ្មៅជ្រលក់ដៃ ដោយមូលហេតុខុមហ្វ្រែលបានធ្វើការសាកល្បងបានជោគជ័យក្នុងការលាងជម្រះទឹកខ្មៅជ្រលក់ដៃបន្ទាប់ពីបោះឆ្នោតរួច ។

ខុមហ្វ្រែលមានការខកចិត្តចំពោះប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ដូចជា ទូរទស្សន៍ជាតិកម្ពុជាក្រោមការគ្រប់គ្រងក្រសួងព័ត៌មានបានធ្វើការផ្សព្វផ្សាយច្រើន ឬលំអៀងទៅរកគណបក្សប្រជាជនកម្ពុជា ដោយការផ្សព្វផ្សាយពីសកម្មភាពអ្នកមានអំណាច សុទ្ធតែមកពីគណបក្សប្រជាជនកម្ពុជានៅថ្ងៃបោះឆ្នោតនៅការិយាល័យបោះឆ្នោត ខណៈដែលគណបក្សផ្សេង ទៀតមិនត្រូវបានផ្សព្វផ្សាយ។

ប៉ុន្តែមានការភ្ញាក់ផ្អើល សោកស្តាយ និងព្រួយបារម្ភជាខ្លាំងមួយទៀតគឺ នៅក្នុងកំឡុងពេលបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ដូចជា វិទ្យុសំបុកឃ្មុំ វិទ្យុសារិការ FM 106.5 ឬកម្មវិធី VOD ត្រូវបានហាមឃាត់ក្នុងការផ្សាយពីព័ត៌មានការបោះឆ្នោត ខណៈពេលដែលប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ឯកជនមួយចំនួនគាំទ្រគណបក្សប្រជាជនកម្ពុជាបានបន្តការផ្សាយអំពីព័ត៌មានបោះឆ្នោត ហើយលំអៀងទៅគណបក្សប្រជាជនកម្ពុជា ។

**បរិយាកាសទូទៅ**

ជាទូទៅ ខុមហ្វ្រែលសង្កេតឃើញថា ដំណើរការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ អាណត្តិទី ៣ ឆ្នាំ ២០១២ នេះ បានប្រព្រឹត្តទៅក្នុងលក្ខណៈរលូន តែប្រជាពលរដ្ឋបានចេញទៅបោះឆ្នោតថយចុះជាងឆ្នាំ ២០០៧។ បើទោះបីការចាត់ចែងដំណើរការបោះឆ្នោត មិនបានជួបភាពមិនប្រក្រតីធ្ងន់ធ្ងររហូតធ្វើឲ្យរាំងស្ទះដល់ដំណើរការបោះឆ្នោតក៏ដោយក៏ ខុមហ្វ្រែលបានរកឃើញភាពមិនប្រក្រតីមួយចំនួនដូចខាងក្រោមនេះ៖

***មុនថ្ងៃបោះឆ្នោតមួយថ្ងៃ "ថ្ងៃស"***

នៅមុនថ្ងៃបោះឆ្នោតមួយថ្ងៃ គឺថ្ងៃទី ០២ មិថុនា ២០១២ បរិយាកាសមានភាពស្ងប់ស្ងាត់ តែទោះបីជាយ៉ាងណា មានការរំលោភបទបញ្ជា និងនីតិវិធីជាពិសេសគឺ ការធ្វើយុទ្ធនាការឃោសនា ករណីទិញសន្លឹកឆ្នោតមានតិចតួច ដោយផ្តល់ជាប្រាក់កាស អំណោយ សម្ភារៈផ្សេងៗ ។ ខុមហ្វ្រែលសង្កេតឃើញថា ទោះបីជាមានសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលពីការផ្អាកលក់ដូរ និងពិសារគ្រឿងស្រវឹងមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣ ក៏ដោយ ប៉ុន្តែក៏នៅមានការរំលោភទៅលើសេចក្តីណែនាំនេះ ជាពិសេសមន្ត្រីការិយាល័យបោះឆ្នោតមួយចំនួន ។

***ថ្ងៃបោះឆ្នោត***

ភាពមិនប្រក្រតី ដែលកើតមានជាញឹកញាប់ និងច្រើនការិយាល័យបោះឆ្នោត និងការប្រព្រឹត្តទៅនៃការបោះឆ្នោតរួមមាន៖

- មានវត្តមានអាជ្ញាធរមូលដ្ឋាន ជាពិសេសអាជ្ញាធរភូមិ នៅជុំវិញការិយាល័យបោះឆ្នោត ដែលអាចជះឥទ្ធិពលទៅលើអ្នកបោះឆ្នោត
- មន្ត្រីការិយាល័យមិនសូវយល់នីតិវិធី និងគោលការណ៍ណែនាំ និងមានការធ្វេសប្រហែស ដូចជាអ្នកបោះឆ្នោតខ្លះមានតែប័ណ្ណព័ត៌មាន ត្រូវបានអនុញ្ញាតឲ្យបោះឆ្នោតបាន ។ មន្ត្រីការិយាល័យខ្លះបានហែកសន្លឹកឆ្នោតទុកមុនការមកដល់របស់អ្នកបោះឆ្នោត ។ ភាពរញេរញៃនៅការិយាល័យបោះឆ្នោត
- ការរកឈ្មោះមិនឃើញ ឬខុសទិន្នន័យអ្នកបោះឆ្នោត
- ការបន្តចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ឲ្យការបោះឆ្នោតនៅខេត្តកំពង់ស្ពឺ
- មានការរារាំងដល់អ្នកសង្កេតការណ៍ចល័តខ្លះ និងអ្នកសារព័ត៌មានខ្លះ

ព័ត៌មានបន្ថែមសូមទាក់ទង

លោក ធន សារាយ ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល ទូរស័ព្ទលេខ ០១៦ ៨៤ ០០ ៨៤

លោក គល់ បញ្ញា នាយកប្រតិបត្តិខុមហ្វ្រែល ទូរស័ព្ទលេខ ០១២ ៩៤ ២០ ១៧